ថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០០៩

# អ្នកជំនាញការអង្គការសហប្រជាជាតិ ៖
# ការបណ្តេញចេញដោយបង្ខំនៅកម្ពុជាធ្វើឱ្យប្រជាពលរដ្ឋរាប់ពាន់នាក់គ្មានផ្ទះសម្បែង

*សេចក្តីថ្លែងការខាងក្រោមស្តីពីការបណ្តេញចេញដោយបង្ខំ ដែលកើតមានជាបន្តបន្ទាប់កាលពីពេលថ្មីៗនេះនៅកម្ពុជា ត្រូវបានចេញនៅថ្ងៃនេះដោយលោក* ***រ៉ាក្អែល រ៉ូលនីត***

*អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមានលំនៅដ្ឋានសមរម្យ*

"នៅយប់ថ្ងៃទី ២៣ និង ២៤ ខែមករា ឆ្នាំ ២០០៩ មានប្រជាពលរដ្ឋជាង ១៣០ គ្រួសារ ត្រូវបានគេបណ្តេញចេញដោយបង្ខំពីតំបន់ដីក្រហមនៅចំកណ្តាលទីក្រុងភ្នំពេញ ដើម្បីឱ្យក្រុមហ៊ុនឯកជនមួយធ្វើការអភិវឌ្ឍន៍ទីតាំងនោះឡើងវិញ។

"ការបណ្តេញចេញដោយបង្ខំនេះ ត្រូវបានធ្វើឡើងនៅពាក់កណ្តាលយប់ ដោយគ្មានការជូនដំណឹងជាមុន ហើយទីជម្រកដែលជាកម្មសិទ្ធិរបស់សហគមន៍ក្រីក្រនេះ ត្រូវបានរុះរើ និងបំផ្លិចបំផ្លាញ។ ស្ថានភាពនេះបានផ្តល់នូវផលវិបាកជាច្រើនដល់ជនរងគ្រោះ ជាពិសេសដល់ស្ត្រី និងកុមារ។ របាយការណ៍ជាច្រើនបានលើកឡើងផងដែរថា សហគមន៍នេះបានទទួលរងនូវការបំភិតបំភ័យ ហើយតំណាងនិងសមាជិកផ្សេងៗរបស់សហគមន៍ទទួលរងនូវការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌផ្សេងៗផងដែរ។

"ជាការគួរឱ្យសោកស្តាយណាស់ ដែលការចរចារផ្សេងៗដើម្បីរកដំណោះស្រាយ ដែលកំពុងកើតមានជាមួយអ្នកភូមិត្រូវបានគេបោះបង់ចោល ដោយធ្វើឱ្យបាត់បង់នូវឱកាសដ៏មានតម្លៃដើម្បីទទួលបាននូវដំណោះស្រាយត្រឹមត្រូវ និងស្របច្បាប់មួយសំរាប់ជម្លោះដ៏យូរអង្វែងនេះ។ ឥឡូវនេះ ការសំខាន់បំផុតគឺថា សិទ្ធិទាំងឡាយរបស់អ្នកភូមិក្នុងការទទួលបានសំណងសមរម្យចំពោះលំនៅដ្ឋាន និងទ្រព្យសម្បត្តិរបស់ពួកគេដែលបានបាត់បង់ និងការផ្តល់ផ្ទះសម្បែងសមរម្យ ត្រូវតែគោរពឱ្យបានពេញលេញ។

"ជាអកុសល្យ នេះមិនមែនមានន័យថាវាជាករណីមួយដាច់ដោយឡែកនោះទេ គឺការកើនឡើងនៃការបណ្តេញចេញដោយបង្ខំទូទាំងប្រទេសកម្ពុជាគឺជារឿងមួយគួរឱ្យភ័យរន្ធត់។ របាយការណ៍ជាច្រើនបង្ហាញថា ប្រជាពលរដ្ឋក្រីក្រ

រាប់ម៉ឺននាក់ ត្រូវបានគេបណ្តេញចេញ និងផ្លាស់លំនៅដ្ឋានដោយបង្ខំ ដែលរុញឱ្យពួកគេធ្លាក់ចូលទៅក្នុងភាពគ្មានផ្ទះសម្បែង និង ទីទាល់ក្របន្ថែមទៀត។

"នៅប្រទេសកម្ពុជា ត្រូវបានគេឃ្លាំមើលដោយយកចិត្តទុកដាក់ទៅលើបែបផែននៃការរំលោភសិទ្ធិដែលកើតមានដដែល១ទាក់ទងនឹងការបណ្តេញចេញដោយបង្ខំផ្សេង១ : ដោយគ្មានដំណោះស្រាយត្រឹមត្រូវ និងការការពារតាមនីតិវិធីផ្លូវច្បាប់ គ្មានសំណងសមរម្យ គ្មានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពជូនសហគមន៍ដែលប្រឈមមុខនឹងការបណ្តេញចេញ ការប្រើប្រាស់កំលាំងច្រើនហួសហេតុ និងការយាយី ការបំភិតបំភ័យ និងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទៅលើអង្គការមិនមែនរដ្ឋាភិបាល និងមេធាវី ដែលធ្វើការទៅលើករណីនេះ។

"ការបណ្តេញចេញដោយបង្ខំទាំងឡាយគឺជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។ ការបណ្តេញចេញដោយបង្ខំអាចឡើងបានតែក្នុងកាលៈទេសៈលើកលែងផ្សេង១ប៉ុណ្ណោះ ហើយត្រូវតែគោរពតាមបទដ្ឋានអន្តរជាតិនានាឱ្យបានពេញលេញ។ ដោយសារជនរងគ្រោះដោយការបណ្តេញចេញដោយបង្ខំទាំងឡាយប្រឈមនឹងបញ្ហាស្ថានភាពមនុស្សធមិយ៉ាងខ្លាំង ខ្ញុំសូមជម្រុញដល់អាជ្ញាធរកម្ពុជានានាឱ្យដាក់ចេញនូវវិធានការថ្នាក់ជាតិមួយដើម្បីផ្អាកការបណ្តេញចេញជាបណ្តោះអាសន្នសិន រង់ចាំរហូតដល់មានគោលនយោបាយ និងវិធានការផ្សេង១សំរាប់ធ្វើការបណ្តេញចេញនេះត្រូវបានបង្កើតឡើងស្របទាំងស្រុងទៅតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។

Ends

*អតីតអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិលំនៅដ្ឋានសមរម្យ បានធ្វើបេសកកម្មមកកាន់ប្រទេសកម្ពុជា ក្នុងឆ្នាំ ២០០៥ ហើយបានបង្ហាញរបាយការណ៍ពីបេសកកម្មស្តីពីការរកឃើញនិងអនុសាសន៍ផ្សេង១ (E/CN.4/2006/41/ Add.3)។ ការព្រួយបារម្ភអំពីការបណ្តេចេញទាំងឡាយនៅកម្ពុជា ត្រូវបានអ្នករាយការណ៍ពិសេសចែករំលែកព័ត៌មាន តាមរយៈការធ្វើទំនាក់ទំនងផ្តល់ព័ត៌មានជាច្រើនលើកជាមួយអាជ្ញាធរនានា។ ការធ្វើទំនាក់ទំនងផ្តល់ព័ត៌មានទាំងនេះនៅមិនទាន់មាន ការឆ្លើយតបនៅឡើយទេ។ សំរាប់ព័ត៌មានបន្ថែមស្តីពីការងារ និងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិលំនៅដ្ឋានសមរម្យសូមមើលគេហទំព័រដែលមានអាស័យដ្ឋាន:*
http://www2.ohchr.org/english/issues/housing/ index.htm

*សំរាប់ព័ត៌មានបន្ថែម ឬសម្ភាសន៍ជាមួយអ្នករាយការណ៍ពិសេស សូមទាក់ទងលោក បារ៉ាម ប្លាស៊ី តាមទូរស័ព្ទលេខ ៤១ ២២ ៩១៧ ៩១ ៧៧ ឬបញ្ជូនសារទៅកាន់* srhousing@ohchr.org ។